ខេមបូចា CamboJA
សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
Cambodian Journalists Alliance Association
(+855) 023 88 23 11
communications@camboja.net
www.camboja.net | www.cambojanews.com

# សេចក្តីប្រកាសព័ត៌មាន

## ការសិក្សាថ្មីមួយរបស់ខេមបូចាបង្ហាញពីផលវិបាកនៃការគំរាមកំហែងលើសិទ្ធិឌីជីថល និង សេរីភាពនៃការបញ្ចេញមតិតាមប្រព័ន្ធអនឡាញនៅកម្ពុជា

*ភ្នំពេញ, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣៖* ការសិក្សាថ្មីមួយរបស់ខេមបូចារកឃើញថា អ្នកសារព័ត៌មាន និងពលរដ្ឋដែលសកម្មលើបណ្តាញអ៊ីនធឺណិត មានការព្រួយបារម្ភទាក់ទងនឹងស្ថានភាពសេរីភាពអ៊ីនធឺណិត សិទ្ធិឌីជីថល និងសុវត្ថិភាពលើប្រព័ន្ធអនឡាញនៅកម្ពុជា។ បន្ថែមលើនេះ បុគ្គលមួយចំនួនបានបង្ហាញពីភាពភ័យខ្លាចចំពោះ ការគំរាមកំហែងដែលអាចប៉ះពាល់ដល់សុវត្ថិភាពផ្ទាល់ខ្លួន ដែលកើតចេញពីអ៊ីនធឺណិតទៀតផង។

ការសិក្សាស៊ីជម្រៅស្តីពី *"ផលប៉ះពាល់នៃការរឹតត្បិតសិទ្ធិឌីជីថលលើសេរីភាពសារព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត"* នេះពិនិត្យលើ ផលប៉ះពាល់នៃការរឹតត្បិតតាមអ៊ីនធឺណិតនៅកម្ពុជាមកលើអ្នកសារព័ត៌មាន និងពលរដ្ឋដែលសកម្មលើបណ្តាញអ៊ីនធឺណិត។ ការសិក្សានេះមានគោលបំណងបង្ហាញពីបញ្ហាប្រឈមរបស់អ្នកសារព័ត៌មាន និងប្រជាពលរដ្ឋ ដែលសកម្មនៅលើប្រព័ន្ធអនឡាញ ដោយសារតែការកំហិតលើសិទ្ធិឌីជីថល។

គោលបំណងចម្បងនៃការសិក្សានេះមានបីចំណុចសំខាន់ៗ៖ ទីមួយ វិភាគ-ឥទ្ធិពលអវិជ្ជមាននៃការរឹតត្បិត មកលើសិទ្ធិឌីជីថល និងសេរីភាពសារព័ត៌មាន ជាពិសេសទាក់ទងនឹងសេរីភាពបញ្ចេញមតិសម្រាប់អ្នកសារព័ត៌មាន និងពលរដ្ឋសកម្មលើអ៊ីនធឺណិត។ ទីពីរ គឺដើម្បីស្វែងរក និងស្វែងយល់ពីទស្សនៈចម្រុះរបស់អ្នកសារព័ត៌មានឯករាជ្យ និងពលរដ្ឋសកម្មតាមអ៊ីនធឺណិតទាក់ទងនឹងផលប៉ះពាល់នៃការរឹតត្បិតសិទ្ធិឌីជីថល។ និងទីបី គឺដើម្បីផ្តល់ឱ្យភាគីពាក់ព័ន្ធនូវការយល់ដឹងឲ្យបានទូលំទូលាយអំពីបញ្ហាទាំងនេះ ជាមួយនិងអនុសាសន៍គោលនយោបាយដើម្បីលើកកម្ពស់ស្ថានភាពសិទ្ធិឌីជីថលរបស់កម្ពុជា។

ខេមរបូចា
សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
Cambodian Journalists Alliance Association
(+855) 023 88 23 11
communications@camboja.net
www.camboja.net | www.cambojanews.com

*ចំណុចសំខាន់ៗពីការសិក្សារួមមាន៖*

*១. **អ៊ីនធឺណិតជាអាវុធមុខពីរ៖** ខណៈអ៊ីនធឺណិតបានក្លាយជាផ្នែកសំខាន់មួយនៃជីវិតរស់នៅក្នុងប្រទេសកម្ពុជា ដែលជួយសម្រួលដល់ការធ្វើទំនាក់ទំនង ការផ្សព្វផ្សាយព័ត៌មាន និងទស្សនៈចម្រុះផ្សេងៗគ្នា ក្តីបារម្ភជុំវិញកំណើននៃការប្រើប្រាស់អ៊ីនធឺណិត និងការឃ្លាំមើលពីសំណាក់រដ្ឋាភិបាល ក៏កំពុងមានការកើនឡើងដែរ។*

*២. **ការយល់ឃើញថាខ្វះសេរីភាពអ៊ីនធឺណិត៖** អ្នកឆ្លើយសំណួរក្នុងការស្រាវជ្រាវបានសម្តែងការព្រួយបារម្ភពីកង្វះ សេរីភាពអ៊ីនធឺណិត ដោយពួកគេយល់ថាមានការឃ្លាំមើលមកលើអ្នកសារព័ត៌មាន និងសកម្មជនពីសំណាក់ រដ្ឋាភិបាល និងក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត* (ISPs)*។*

*៣. **ការព្រួយបារម្ភអំពីឧបករណ៍ច្បាប់៖** អ្នកឆ្លើយសំណួរភាគច្រើនបានសម្តែងក្តីព្រួយបារម្ភខ្លាចរដ្ឋាភិបាលប្រើប្រាស់ច្បាប់ជាឧបករណ៍ក្នុងការរឹតត្បិតសកម្មភាពលើបណ្តាញអ៊ីនធឺណិត ដោយបង្ហាញពីកង្វល់ជុំវិញផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន មកលើសេរីភាពនៃការបញ្ចេញមតិ។*

*៤. **ការរាំងដល់ការច្នៃប្រឌិត៖** ខណៈមានការទទួលស្គាល់ពីសក្តានុពលអ៊ីនធឺណិតសម្រាប់ការស្វែងយល់ពីទស្សនៈផ្សេងៗគ្នា អ្នកឆ្លើយសំណួរបានគូសបញ្ជាក់ពីរបៀបដែលការកំហិតនាពេលបច្ចុប្បន្ននេះបានរាំងដល់ការច្នៃប្រឌិត និងរឹតបន្តឹងការទទួលបានព័ត៌មានសំខាន់ៗសម្រាប់ប្រជាពលរដ្ឋ និងអ្នកបង្កើតគោលនយោបាយ។*

*៥. **ការគំរាមកំហែងផ្នែកសន្តិសុខ និងការរឹតត្បិតខ្លួនឯង៖** ការបារម្ភពីការគំរាមកំហែងមកលើសុវត្ថិភាព និងសន្តិសុខផ្ទាល់ខ្លួន ដែលកើតចេញពីសកម្មភាពលើប្រព័ន្ធអនឡាញ គឺជា*

កង្វល់ដ៏ធំមួយ ដែលជះឥទ្ធិពលដល់កម្រិតផាសុកភាព និងអាចនាំទៅដល់ការរឹតត្បិតខ្លួនឯង ជាពិសេសការផ្សព្វផ្សាយព័ត៌មានរសើបៗពាក់ព័ន្ធនឹងនយោបាយ។

៦. **ការព្រួយបារម្ភអំពីសន្តិសុខឌីជីថល៖** អ្នកឆ្លើយសំណួរបានបង្ហាញការព្រួយបារម្ភពីការទាញយកទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់អ៊ីនធឺណិត (big data mining) ការវាយប្រហារដោយប្រើមេរោគ Malware និងការឃ្លាំមើលពីសំណាក់រដ្ឋាភិបាល ដែលទាំងនេះរួមចំណែកដល់ការបង្កបរិយាកាសមិនល្អ។

លោក ណុប វី នាយកប្រតិបត្តិ ខេមបូចា ថ្លែងថា៖ "ខ្ញុំគិតថារបាយការណ៍នេះមានសារៈសំខាន់ណាស់សម្រាប់រដ្ឋាភិបាល និងភាគីពាក់ព័ន្ធក្នុងការស្វែងយល់ពីតម្រូវការ កង្វល់ជុំវិញសិទ្ធិឌីជីថល និងសេរីភាពអ៊ីនធឺណិត ដែលគួរតែត្រូវបានដោះស្រាយតាមរយៈអនុសាសន៍ដែលបានផ្តល់ជូននេះ"។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

លោក ណុប វី នាយកប្រតិបត្តិខេមបូចា
លេខទូរសព្ទ៖ (+៨៥៥) ១២ ៥១៩ ២៦១ (Signal)
អ៊ីមែល៖ ed@camboja.net (ភាសាខ្មែរ និងអង់គ្លេស)

**លោកអ្នកអាចទាញយករបាយការណ៍ពេញតាមរយៈការស្កេនQR Code ខាងក្រោមនេះ៖**